# ព្រះរាជក្រម

នស/រកម/១០០៥/០៣២

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

-បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១០៥/០០២ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥ ដែលប្រកាស ឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា និងរបស់រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីការអនុម័តយល់ព្រមលើអនុសញ្ញារបស់អង្គការសហប្រជាជាតិ ខាងការងារលេខ១៨២ ស្តីពីការហាមប្រាម និងសកម្មភាពបន្ទាន់សម្រាប់ការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុត នៃពលកម្មកុមារ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០៥ នាសម័យប្រជុំរដ្ឋសភាលើកទី ៣ នីតិកាលទី ៣ និងព្រឹទ្ធសភាបានអនុម័តយល់ស្របលើទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០០៥ នាសម័យប្រជុំពេញអង្គលើកទី ១០ នីតិកាលទី ១ ដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ :

# ច្បាប់
## ស្តីពី
## ការអនុម័តយល់ព្រមលើអនុសញ្ញារបស់អង្គការអន្តរជាតិខាងការងារ លេខ ១៨២ ស្តីពីការហាមប្រាម និងសកម្មភាពបន្ទាន់សម្រាប់ ការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ

មាត្រា ១.-

អនុម័តយល់ព្រមលើអនុសញ្ញារបស់អង្គការអន្តរជាតិខាងការងារលេខ ១៨២ ស្តីពីការហាមប្រាមនិងសកម្មភាពបន្ទាន់សម្រាប់ការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ ដែលអនុម័តដោយសន្និសីទអន្តរជាតិខាងការងារ ក្នុងសម័យប្រជុំលើកទី ៨៧ នាថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ១៩៩៩ នៅទីក្រុងហ្សឺណែវ ហើយដែលមានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយនេះ ។

មាត្រា ២.-

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបន្តរាល់នីតិវិធីដើម្បីអនុវត្តអនុសញ្ញានេះ ។

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែតុលា ឆ្នាំ ២០០៥

ពរក.០៤១០-៤៧៥ ព្រះហស្ថលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្ថលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រី

ហត្ថលេខា

ហ៊ុន សែន

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

ហត្ថលេខា

ញ៉ឹប ទុនជិន

លេខៈ ៤២៩ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ០២ ខែ វិច្ឆិកា ឆ្នាំ២០០៥

អគ្គលេខាធិការរាជរដ្ឋាភិបាល

ណោម តាន់

អនុសញ្ញាលេខ ១៨២

# អនុសញ្ញាស្តីពីការហាមប្រាម និងសកម្មភាពបន្ទាន់សំរាប់ការលុបបំបាត់ ទំរង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ

**មហាសន្និបាតអង្គការអន្តរជាតិខាងការងារ**

- ដោយបានកោះប្រជុំនៅទីក្រុងហ្សឺណែវ ដោយក្រុមប្រឹក្សាភិបាលនៃការិយាល័យអន្តរជាតិខាងការងារ និង ដោយបានរួមប្រជុំនាថ្ងៃទី ១ ខែ មិថុនា ឆ្នាំ ១៩៩៩ ក្នុងសម័យប្រជុំលើកទី ៨៧និង

- ដោយយល់ឃើញថា ដល់ពេលអនុម័តឯកសារឧបករណ៍ថ្មីសំរាប់ការហាមប្រាម និងសកម្មភាពបន្ទាន់សំរាប់ការលុបបំបាត់ទំរង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារប្រកបដោយប្រសិទ្ធិភាព ដែលជាអាទិភាពចំបងសំរាប់សកម្មភាព ជាតិ និងអន្តរជាតិ រួមមាន កិច្ចសហប្រតិបត្តិការនិងជំនួយឧបត្ថម្ភជាអន្តរជាតិ និងដើម្បីបំពេញបន្ថែមនូវអនុសញ្ញា និងអនុសាសន៍ស្តីពីអាយុអប្បបរមាសំរាប់ចូលធ្វើការងារឆ្នាំ ១៩៧៣ ដែលនៅតែជាឧបករណ៍គ្រឹះ ពលកម្មកុមារ និង

- ដោយយល់ឃើញថា ការលុបបំបាត់ទំរង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារប្រកបដោយប្រសិទ្ធិភាពតំរូវឱ្យមាននូវសកម្មភាពជាបន្ទាន់ និងទូលំទូលាយដែលនឹងយកចិត្តទុកដាក់នូវសារៈសំខាន់នៃការអប់រំជាមូលដ្ឋានដោយឥតបង់ថ្លៃ និង សេចក្តីត្រូវការដើម្បីដកយកកុមារពាក់ព័ន្ធចេញពីកន្លែងធ្វើការងារ និងដើម្បីផ្តល់អោយពួកគេនូវការស្តារនីតិសម្បទា និងការធ្វើសមាហរណកម្មទៅក្នុងសង្គម ខណៈដែលនឹងឆ្លើយតបនូវសេចក្តីត្រូវការនៃគ្រួសាររបស់គេ និង

- ដោយរំលឹកឡើងវិញនូវ ដំណោះស្រាយស្តីពីការលុបបំបាត់ពលកម្មកុមារ ត្រូវបានអនុម័តដោយសន្និសីទអន្តរជាតិខាងការងារនៅសម័យប្រជុំលើកទី ៨៣ ក្នុងឆ្នាំ ១៩៩៦ និង

- ដោយទទួលស្គាល់ថា ពលកម្មកុមារគឺជាទំហំដ៏ធំធេងដែលបណ្តាលមកពីភាពក្រីក្រ និងជាដំណោះស្រាយយូរអង្វែងដែលពឹងផ្អែកទាំងស្រុងទៅលើការរីកលូតលាស់សេដ្ឋកិច្ចប្រកបដោយនិរន្តរភាពដែលនាំដល់ ការរីកចំរើនផ្នែកសង្គម ជាពិសេស ការកាត់បន្ថយភាពក្រីក្រ និងការអប់រំជាសាកល និង

- ដោយរំលឹកឡើងវិញនូវ អនុសញ្ញាស្តីពីសិទ្ធិកុមារត្រូវបានអនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិ នៅថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ ១៩៨៩ និង

- ដោយរំលឹកឡើងវិញនូវ សេចក្តីប្រកាសរបស់អង្គការអន្តរជាតិខាងការងារស្តីពីគោលការណ៍គ្រឹះ និង សិទ្ធិធ្វើការងារ និងការអនុវត្តន៍បន្តត្រូវបានអនុម័តដោយសន្និសីទអន្តរជាតិខាងការងារក្នុងសម័យប្រជុំទី ៨៦ ក្នុងឆ្នាំ ១៩៩៨ និង

- ដោយរំលឹកឡើងវិញនូវ ទំរង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារមួយចំនួនត្រូវបានគ្របដណ្តប់ដោយបរិធានអន្តរជាតិផ្សេងៗទៀត ជាពិសេស អនុសញ្ញាស្តីពីការងារដោយបង្ខំ នៅឆ្នាំ ១៩៣០ និងអនុសញ្ញាបំពេញបន្ថែមរបស់អង្គការសហប្រជាជាតិស្តីពីការលុបបំបាត់ទាសភាព ការធ្វើអាជីវកម្មទាសករ ព្រមទាំងការប្រព្រឹត្ត និងការអនុវត្តន៍ប្រហាក់ប្រហែលទៅនឹងទាសភាព នៅឆ្នាំ ១៩៥៦ និង

ដោយបានសំរេចលើការអនុម័តនៃសំណើរជាក់លាក់មួយចំនួនពាក់ព័ន្ធទៅនឹងពលកម្មកុមារដែលជារបៀបវារៈទី ៤នៃសម័យ ប្រជុំ និង

- ដោយបានកំណត់ថា សំណើទាំងនេះនឹងរៀបចំជាទំរង់បែបបទនៃអនុសញ្ញាអន្តរជាតិសន្និសិទ្ធសំរេចអនុម័ត នៅថ្ងៃទី ដប់ប្រាំពីរ ខែមិថុនា ឆ្នាំមួយពាន់ប្រាំបួនរយកៅសិបប្រាំបួន នូវអនុសញ្ញាខាងក្រោមដែលមានឈ្មោះថាអនុសញ្ញា ស្តីពីទំរង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ ១៩៩៩៖

## មាត្រា ១

រដ្ឋជាសមាជិកនីមួយៗ ដែលផ្តល់សច្ចាប័នលើអនុសញ្ញានេះ ត្រូវចាត់វិធានការបន្ទាន់ និងមានប្រសិទ្ធិភាពដើម្បីធានាដល់ការហាមប្រាម និងការលុបបំបាត់ទំរង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារដែលជាបញ្ហាបន្ទាន់។

## មាត្រា ២

សំរាប់គោលបំណងនៃអនុសញ្ញានេះ ពាក្យថា "កុមារ" ត្រូវអនុវត្តចំពោះមនុស្សគ្រប់រូបដែលមានអាយុ ក្រោម ១៨ឆ្នាំ ។

## មាត្រា ៣

សំរាប់គោលបំណងនៃអនុសញ្ញានេះ ពាក្យថា "ទំរង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ" រួមមាន៖

(ក) គ្រប់ទំរង់ទាំងអស់នៃទាសភាព ឬការអនុវត្តន៍ប្រហាក់ប្រហែលទៅនឹងទាសភាព ដូចជា ការលក់ និងការជួញដូរកុមារ ការងារដោះបំណុល និងការងារជាខ្ញុំកញ្ជះគេដាច់ថ្លៃ ការងារដោយបង្ខំ

ឬការងារដោយកាតព្វកិច្ច រួមទាំង ការជ្រើសរើសកុមារ ដោយបង្ខំ ឬដោយកាតព្វកិច្ចដើម្បីអោយបំរើក្នុងជំលោះប្រដាប់អាវុធ ។

(ខ) ការប្រើប្រាស់ ការអូសទាញ ឬការផ្តល់អោយកុមារបំរើក្នុងបេស្យាកម្ម ការផលិតរូបភាពអាសគ្រាម ឬការសំដែងអាសគ្រាម ។

(គ) ការប្រើប្រាស់ ការអូសទាញ ឬផ្តល់អោយកុមារបំរើក្នុងសកម្មភាពខុសច្បាប់ ជាពិសេសការផលិត និងការ ជួញដូរគ្រឿងញៀន ដូចដែលបានកំណត់ក្នុងសន្ធិសញ្ញាអន្តរជាតិពាក់ព័ន្ធនានា ។

(ឃ) ការងារទាំងឡាយណាដែលលក្ខណៈ ឬស្ថានភាពរបស់វានៅពេលដែលត្រូវបានគេអនុវត្តអាចនឹងបណ្តាលឱ្យប៉ះពាល់ដល់សុខភាព សុវត្ថិភាព ឬសីលធម៌របស់កុមារ ។

## មាត្រា ៤

១- ប្រភេទនៃការងារដែលបានចែងក្នុងមាត្រា ៣ (ឃ) ត្រូវបានកំណត់ដោយច្បាប់ជាតិ ឬបទបញ្ញត្តិ ឬដោយអាជ្ញាធរមានសមត្ថកិច្ច ក្រោយពីបានប្រឹក្សាយោបល់ជាមួយអង្គការនិយោជក និង កម្មករ និយោជិតដែលពាក់ព័ន្ធ ដោយយកចិត្តទុកដាក់ពិចារណាទៅលើបទដ្ឋានអន្តរជាតិដែលពាក់ព័ន្ធ ជាពិសេស វាក្យខ័ណ្ឌទី ៣ និងទី ៤ នៃអនុសាសន៍ស្តីពីទំរង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ ឆ្នាំ ១៩៩៩។

២- ក្រោយពីបានប្រឹក្សាយោបល់ជាមួយអង្គការនិយោជក និងកម្មករនិយោជិតដែលពាក់ព័ន្ធរួចមក អាជ្ញាធរមានសមត្ថកិច្ចត្រូវកំណត់ថាតើប្រភេទការងារណាត្រូវកំណត់ជាទំរង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ ។

៣- បញ្ជីនៃប្រភេទការងារដែលបានកំណត់នៅក្នុងវាក្យខ័ណ្ឌទី ១នៃមាត្រានេះ ត្រូវពិនិត្យ និងកែសំរួលឡើងវិញជាទៀងទាត់ ប្រសិនបើចាំបាច់ ដោយប្រឹក្សាយោបល់ជាមួយអង្គការនិយោជក និងកម្មករនិយោជិតដែលពាក់ព័ន្ធ។

## មាត្រា ៥

បន្ទាប់ពីប្រឹក្សាយោបល់ជាមួយអង្គការនិយោជក និងកម្មករនិយោជិត រដ្ឋជាសមាជិកនីមួយៗ ត្រូវបង្កើតឡើង ឬចាត់តាំងយន្តការដ៏សមស្របដើម្បីពិនិត្យតាមដានការអនុវត្តនូវបទប្បញ្ញត្តិ ដែលផ្តល់ប្រសិទ្ធិភាពដល់អនុសញ្ញានេះ ។

## មាត្រា ៦

១- រដ្ឋជាសមាជិកនីមួយៗ ត្រូវរៀបចំ និងអនុវត្តកម្មវិធីសកម្មភាពនានា ដើម្បីលុបបំបាត់ទំរង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារដែលជាអាទិភាព ។

២- កម្មវិធីសកម្មភាពទាំងនោះ ត្រូវបានរៀបចំ និងអនុវត្ត ដោយមានការប្រឹក្សាយោបល់ជាមួយស្ថាប័នរដ្ឋាភិបាលពាក់ព័ន្ធ អង្គការនិយោជក និងកម្មករនិយោជិត យកចិត្តទុកដាក់ពិចារណាលើទស្សនៈ របស់ ក្រុមពាក់ព័ន្ធដទៃៗទៀតអោយបានសមស្រប ។

## មាត្រា ៧

១- រដ្ឋជាសមាជិកនីមួយៗ ត្រូវចាត់គ្រប់វិធានការចាំបាច់ ដើម្បីធានាការអនុវត្តបទប្បញ្ញត្តិនានាដែល ផ្តល់ប្រសិទ្ធិភាពដល់អនុសញ្ញានេះរួមទាំង បទប្បញ្ញត្តិ និងការអនុវត្តទោសព្រហ្មទណ្ឌ ឬទោស ទណ្ឌកម្មផ្សេងៗទៀតអោយបានសមស្រប ។

២- រដ្ឋជាសមាជិកនីមួយៗ ត្រូវយកចិត្តទុកដាក់លើសារៈសំខាន់នៃការអប់រំក្នុងការលុបបំបាត់ពលកម្មកុមារ ដោយប្រកាន់យកនូវវិធានការប្រកបដោយប្រសិទ្ធិភាព និងមានពេលវេលាកំណត់ដើម្បី :

(ក) ទប់ស្កាត់នូវការចូលរួមរបស់កុមារនៅក្នុងទំរង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ ។

(ខ) ផ្តល់ជំនួយឧបត្ថម្ភដោយផ្ទាល់ដែលចាំបាច់ និងសមស្រប សំរាប់ការដកហូតកុមារចេញពីទំរង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ និង ផ្តល់ការស្តារនីតិសម្បទាព្រមទាំងធ្វើសមាហរណកម្មពួកគេទៅក្នុងសង្គមវិញ ។

(គ) ធានាលទ្ធភាពទទួលបានការអប់រំជាមូលដ្ឋានដោយឥតគិតថ្លៃ ប្រសិនបើ និង បើអាចធ្វើទៅបាន

គឺផ្តល់ការបណ្តុះបណ្តាលវិជ្ជាជីវៈសមស្របសំរាប់កុមារទាំងអស់ដែលបានដកហូតចេញពីទំរង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ ។

(ឃ) កំណត់ និង ចាត់វិធានការចំពោះកុមារងាយរងគ្រោះពិសេស និង

(ង) យកចិត្តទុកដាក់ចំពោះស្ថានភាពពិសេសរបស់កុមារី ។

៣- រដ្ឋជាសមាជិកនីមួយៗ ត្រូវចាត់តាំងអាជ្ញាធរមានសមត្ថកិច្ច អោយទទួលខុសត្រូវចំពោះការអនុវត្តបទប្បញ្ញត្តិទាំងនេះដែលផ្តល់ប្រសិទ្ធិភាពដល់អនុសញ្ញានេះ ។

## មាត្រា ៨

រដ្ឋជាសមាជិកទាំងឡាយត្រូវចាត់វិធានការសមស្របនានា ដើម្បីជួយគ្នាទៅវិញទៅមកក្នុងការផ្តល់ប្រសិទ្ធិភាពដល់បទប្បញ្ញត្តិនៃអនុសញ្ញានេះតាមរយៈការធ្វើអោយប្រសើរឡើងនូវកិច្ចសហប្រតិបត្តិការអន្តរជាតិដ៏ ឬជំនួយឧបត្ថម្ភ រួមទាំង ការគាំទ្រសំរាប់ការអភិវឌ្ឍន៍សង្គមនិងសេដ្ឋកិច្ច កម្មវិធីលុបបំបាត់ភាពក្រីក្រ និងការ អប់រំជាសកល ។

## មាត្រា ៩

ការផ្តល់សច្ចាប័នជាផ្លូវលើអនុសញ្ញានេះ
ត្រូវទំនាក់ទំនងជូនដំណឹងទៅអគ្គនាយកនៃការិយាល័យអន្តរជាតិខាងការ ងារសំរាប់ ការចុះបញ្ជីកា ។

## មាត្រា ១០

១- អនុសញ្ញានេះ
ត្រូវចងភ្ជាប់តែទៅលើរដ្ឋជាសមាជិកនៃអង្គការអន្តរជាតិខាងការងារទាំងឡាយណា ដែលការផ្តល់សច្ចាប័នត្រូវបានចុះបញ្ជីកាជាមួយអគ្គនាយកនៃការិយាល័យអន្តរជាតិខាងការងារ ប៉ុណ្ណោះ។

២- អនុសញ្ញានេះនឹងចូលជាធរមាន រយៈពេល ១២ខែ ក្រោយកាលបរិច្ឆេទដែលការផ្តល់សច្ចាប័ននៃសមាជិកចំនួនពីរ ត្រូវបានចុះបញ្ជិកាជាមួយអគ្គនាយក ។

៣- ក្រោយមក អនុសញ្ញានេះ នឹងចូលជាធរមានសំរាប់រដ្ឋជាសមាជិកណាក៏ដោយ រយៈពេល១២ខែ ក្រោយកាលបរិច្ឆេទដែលការផ្តល់សច្ចាប័នត្រូវបានចុះបញ្ជីកា ។

## មាត្រា ១១

១- សមាជិកមួយដែលបានផ្តល់សច្ចាប័នលើអនុសញ្ញានេះរួចហើយ អាចបដិសេធវិញ បន្ទាប់ពីការផុតកំណត់រយៈពេល ១០ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទដែលអនុសញ្ញានេះចូលជាធរមានលើកដំបូងបង្អស់ តាមរយៈបទបញ្ញត្តិដែលអោយដំណឹងទៅអគ្គនាយកនៃការិយាល័យអន្តរជាតិខាងការងារសំរាប់ការចុះបញ្ជីកា ។ សេចក្តីបដិសេធនេះនឹងមិនចូលជាធរមានរហូតរយៈពេល ១ឆ្នាំ ក្រោយកាលបរិច្ឆេទដែលអនុសញ្ញានេះត្រូវបានចុះបញ្ជីកា ។

២- រដ្ឋជាសមាជិកនីមួយៗ ដែលបានផ្តល់សច្ចាប័នលើអនុសញ្ញានេះរួចហើយ ហើយដែលមិនបាន អនុវត្តនូវ សិទ្ធិបដិសេធដែលចែងនៅក្នុងមាត្រានេះក្នុងកំឡុងពេល ១ឆ្នាំ ដែលចែងនូវការផុតកំណត់ នៃកំឡុង ពេល ១០ ឆ្នាំ ដូចមានចែងនៅក្នុងកថាខ័ណ្ឌមុនៗ នឹងត្រូវលើកសិទ្ធិបដិសេធនេះសំរាប់ កំឡុងពេល ១០ឆ្នាំ ក្រោយទៀត ហើយបន្ទាប់មក ទើបអាចមានសិទ្ធិបដិសេធអនុសញ្ញានេះ នៅពេលផុតកំណត់ នៃកំឡុងពេល ១០ឆ្នាំក្រោមល័ក្ខខ័ណ្ឌ ដូចមានចែងក្នុងមាត្រានេះ ។

## មាត្រា ១២

១- អគ្គនាយកនៃការិយាល័យអន្តរជាតិខាងការងារ នឹងជូនដំណឹងទៅគ្រប់រដ្ឋសមាជិកទាំងអស់នៃ អង្គការអន្តរជាតិខាងការងារអំពីការចុះបញ្ជីកាលើរាល់ការផ្តល់សច្ចាប័ន និងបទប្បញ្ញត្តិបដិសេធ ដែលរដ្ឋសមាជិកនៃអង្គការនេះបានបញ្ជូនមកឱ្យខ្លួន ។

២- នៅពេលជូនដំណឹងទៅអោយរដ្ឋសមាជិកនៃអង្គការនេះ អំពីការចុះបញ្ជីកានៃការផ្តល់សច្ចាប័ន លើកទីពីរ អគ្គនាយកត្រូវទាក់ទាញចំណាប់អារម្មណ៍នៃរដ្ឋសមាជិកទាំងឡាយរបស់អង្គការនេះ ចំពោះកាលបរិច្ឆេទដែលអនុសញ្ញានឹងចូលជាធរមាន ។

## មាត្រា ១៣

អគ្គនាយកនៃការិយាល័យអន្តរជាតិខាងការងារ ត្រូវផ្តល់ដំណឹងទៅអគ្គលេខាធិការនៃអង្គការ សហប្រជាជាតិ សំរាប់ការចុះបញ្ជីកាដោយអនុលោមតាមមាត្រា ១០២ នៃធម្មនុញ្ញរបស់អង្គការ សហប្រជាជាតិនូវរាល់ ចំណុចពិស្តារពេញលេញនៃការផ្តល់សច្ចាប័នទាំងអស់ និងបទប្បញ្ញត្តិបដិសេធ ដែលចុះបញ្ជីកាដោយអគ្គនាយក ដោយអនុលោមតាមបទប្បញ្ញត្តិនៃមាត្រាមុនៗ ។

## មាត្រា ១៤

នៅក្នុងពេលវេលាមួយដែលយល់ថាចាំបាច់ ក្រុមប្រឹក្សាភិបាលនៃការិយាល័យអន្តរជាតិខាងការងារ ត្រូវបង្ហាញ ជូនមហាសន្និបាតនូវរបាយការណ៍ស្តីពីការអនុវត្តលើអនុសញ្ញានេះ ហើយត្រូវពិនិត្យមើលពីបំណង ប្រាថ្នានៃការ ដាក់បញ្ចូលក្នុងរបៀបវារៈនៃសន្និសីទនូវសំណួរនៃការកែប្រែអនុសញ្ញានេះទាំងមូល ឬមួយ ផ្នែក។

## មាត្រា ១៥

១- នៅក្នុងករណីដែលមហាសន្និបាតអនុម័តលើអនុសញ្ញាថ្មីមួយដែលកែប្រែអនុសញ្ញានេះ ទាំងមូល ឬដោយផ្នែក វៀរលែងតែអនុសញ្ញាថ្មីនេះមានចែងថា :

(ក) ការផ្តល់សច្ចាប័នដោយរដ្ឋសមាជិកនៃអនុសញ្ញាកែប្រែថ្មី នឹងនាំទៅដល់ការបដិសេធ អនុសញ្ញានេះភ្លាមដោយពេញច្បាប់ និងដោយមិនគិតទៅដល់បទប្បញ្ញត្តិនៃមាត្រា ១១ ខាងលើ ប្រសិនបើ និងនៅពេលដែលអនុសញ្ញាកែប្រែថ្មីនេះចូលជាធរមាន ។

(ខ) ចាប់តាំងពីកាលបរិច្ឆេទដែលអនុសញ្ញាកែប្រែថ្មីចូលជាធរមាន អនុសញ្ញានេះនឹងត្រូវបញ្ចប់ ការបើកចំហចំពោះការផ្តល់សច្ចាប័នដោយរដ្ឋសមាជិក ។

២- ទោះក្នុងករណីណាក៏ដោយ អនុសញ្ញានេះនឹងនៅជាធរមានដដែល ទាំងទំរង់ និងខ្លឹមសារ ជាក់ស្តែងរបស់ខ្លួនសំរាប់រដ្ឋសមាជិកទាំងឡាយណា ដែលបានផ្តល់សច្ចាប័នលើអនុសញ្ញារួច ហើយ ប៉ុន្តែមិនបានផ្តល់សច្ចាប័នលើអនុសញ្ញាកែប្រែថ្មីឡើយ ។

## មាត្រា ១៦

ទាំងអត្ថបទជាភាសាអង់គ្លេស និងបារាំងនៃអនុសញ្ញានេះ គឺ មានតំលៃស្មើគ្នា ។

អនុសាសន៍ ១៩០

## អនុសាសន៍ស្តីពីការហាមឃាត់ និងសកម្មភាពបន្ទាន់ សំរាប់លុបបំបាត់នូវទំរង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ

**មហាសន្និបាតអង្គការអន្តរជាតិខាងការងារ :**

- ដោយបានកោះប្រជុំនៅទីក្រុងហ្សឺណែវ ដោយក្រុមប្រឹក្សាភិបាលនៃការិយាល័យអន្តរជាតិខាងការងារ និង ដោយបានរួម ប្រជុំ នាថ្ងៃទី ០១ ខែ មិថុនា ឆ្នាំ ១៩៩៩ ក្នុងសម័យប្រជុំលើកទី ៨៧ និង
- ក្រោយពីបានសំរេចអនុម័តលើអនុសញ្ញាស្តីពីទំរង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ ឆ្នាំ ១៩៩៩ និង
- ក្រោយពីបានសំរេចអនុម័តលើសំណើរសុំមួយចំនួនពាក់ព័ន្ធទៅនឹងពលកម្មកុមារដែលជារបៀបវារៈទី ៤ នៃសន្និសីទ និង
- ក្រោយពីបានកំណត់ថា សំណើរសុំទាំងនេះ នឹងមានទំរង់បែបបទជាអនុសាសន៍មួយបំពេញបន្ថែមទៅលើ អនុសញ្ញាស្តីពីទំរង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ ឆ្នាំ ១៩៩៩

អនុម័តនៅថ្ងៃទីដប់ប្រាំពីរ ខែមិថុនា ឆ្នាំមួយពាន់ប្រាំបួនរយកៅសិបប្រាំបួន នូវអនុសាសន៍ស្តីពីទំរង់ធ្ងន់ធ្ងរ បំផុតនៃពលកម្មកុមារ ឆ្នាំ ១៩៩៩ ដូចមានចែងខាងក្រោម:

១. បទបញ្ញត្តិនានានៃអនុសាសន៍នេះ បំពេញបន្ថែមទៅលើអនុសញ្ញាស្តីពីទំរង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ ឆ្នាំ ១៩៩៩ (ចាប់ពីពេលនេះតទៅ យើងហៅថា"អនុសញ្ញា") នឹងត្រូវអនុវត្តន៍ដោយផ្សាភ្ជាប់ ជាមួយនឹងអនុសាសន៍ ទាំងនេះ ។

## I. កម្មវិធីសកម្មភាព

២. កម្មវិធីសកម្មភាពដូចមានចែងក្នុងមាត្រា ៦ នៃអនុសញ្ញានេះ នឹងត្រូវរៀបចំឡើង និងអនុវត្តជាការប្រញាប់ ដោយពិគ្រោះយោបល់ជាមួយស្ថាប័នរដ្ឋាភិបាលពាក់ព័ន្ធ និងអង្គការនិយោជក សហជីព ដោយពិចារណាទៅលើ ទស្សនៈរបស់កុមារដែលរងគ្រោះដោយ ទំរង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ គ្រួសាររបស់ពួកគេ និងក្រុមពាក់ព័ន្ធ ផ្សេងៗទៀតដែលបានប្តេជ្ញាចិត្តចំពោះគោលបំណងនៃអនុសញ្ញា និងអនុសាសន៍នេះ ។ កម្មវិធីទាំងនេះ គួរមាន គោលបំណងអន្តរទំនាក់ទំនង ដូចតទៅ:

(ក) ធ្វើការកំណត់ និងប្រកាសអំពីទំរង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ

(ខ) ការពារទប់ស្កាត់កុំឱ្យកុមារចូលរួមនៅក្នុង និងដកហូតពួកគេចេញពីទំរង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ, ការ ពារពួកគេពីការរងគ្រោះឈឺចាប់ទាំងឡាយ និងផ្តល់ការស្តារនីតិសម្បទា និងសមាហរណកម្មពួកគេទៅ ក្នុងសង្គម តាមរយៈវិធានការនានាសំដៅឆ្លើយតបទៅនឹងសេចក្តីត្រូវការខាងអប់រំ ការអភិវឌ្ឍន៍រាងកាយ និងចិត្តសាស្ត្រ ។

(គ) ផ្តល់ការយកចិត្តទុកដាក់ពិសេសចំពោះ :

(i) កុមារវ័យក្មេង

(ii) កុមារី

(iii) បញ្ហានៃការងារស្ថិតក្នុងស្ថានភាពអាថ៌កំបាំង ដែលក្នុងនោះកុមារីងាយទទួលរងគ្រោះជាពិសេស

(iv) ក្រុមកុមារផ្សេងៗទៀតដែលស្ថិតនៅក្នុងស្ថានភាពងាយរងគ្រោះ ឬសេចក្តីត្រូវការពិសេស ។

(ឃ) ធ្វើការកំណត់ ចុះផ្សាល់ និងធ្វើការជាមួយសហគមន៍ ទីកន្លែងដែលកុមារងាយរងគ្រោះជាពិសេស ។

(ង) ផ្តល់ព័ត៌មាន ធ្វើឱ្យយល់ដឹងប្រាប និងចលនាមតិសាធារណៈ និងក្រុមដែលពាក់ព័ន្ធ រួមបញ្ចូលទាំងកុមារ និងគ្រួសាររបស់ពួកគេ ។

## II. ការងារប្រកបដោយគ្រោះថ្នាក់

២. ក្នុងការកំណត់ប្រភេទនៃការងារដែលបានលើកឡើងនៅក្នុង មាត្រា ៣ (ឃ) នៃអនុសញ្ញា និងក្នុងការកំណត់អំពីទីកន្លែងដែលប្រភេទការងារទាំងនោះកើតមានឡើង, ការយកចិត្តទុកដាក់ គួរផ្តោតទៅលើអន្តរទំនាក់ទំនងការងារ ដូចខាងក្រោម:

(ក) ការងារដែលធ្វើឱ្យកុមារទទួលរងនូវការរំលោភបំពានផ្នែករាងកាយ ចិត្តសាស្ត្រ ឬខាងផ្លូវភេទ ។

(ខ) ការងារក្រោមដី ក្រោមទឹក និងទីខ្ពស់ដែលប្រកបដោយគ្រោះថ្នាក់ ឬទីកន្លែងចង្អៀត ។

(គ) ការងារជាមួយម៉ាស៊ីន ឧបករណ៍និងសម្ភារៈដែលប្រកបដោយគ្រោះថ្នាក់ ឬការងារដែលពាក់ព័ន្ធទៅនឹងការប្រើប្រាស់កំលាំងពលកម្ម ឬការដឹកជញ្ជូនវត្ថុធ្ងន់ៗ ។

(ឃ)ការងារនៅក្នុងបរិស្ថានគ្មានអនាម័យ ឧទាហរណ៍ អាចធ្វើឱ្យកុមារងាយទទួលរងគ្រោះចំពោះសារធាតុ ឬខ្សែសង្វាក់ផលិតកម្ម ឬសីតុណ្ហភាព ឬកំរិតសំឡេង ឬ ភាពរំញ័រដែលប្រកបដោយគ្រោះថ្នាក់ដែលអាចបំផ្លិចបំផ្លាញដល់សុខភាព របស់កុមារ ។

(ង) ការងារនៅក្នុងល័ក្ខខ័ណ្ឌពិបាក ដូចជា ធ្វើការងារច្រើនម៉ោង ឬការងារពេលយប់ ឬការងារដែលកុមារត្រូវបានបង្ខាំងទុកដោយមិនសមហេតុផលនៅទីកន្លែងធ្វើការ ដោយនិយោជក ។

៤. ប្រភេទការងារលើកឡើងនៅក្នុងមាត្រា ៣ (ឃ) នៃអនុសញ្ញា និងវាក្យខ័ណ្ឌ ៣ ខាងលើ, ច្បាប់ជាតិ ឬ បទបញ្ញត្តិ ឬអាជ្ញាធរមានសមត្ថកិច្ច ក្រោយពីការពិគ្រោះយោបល់ជាមួយអង្គការនិយោជក សហជីពដែលពាក់ព័ន្ធ អាចកំណត់មុខរបរ ឬការងារ សំរាប់កុមារចាប់ពីអាយុ ១៦ឆ្នាំ ឡើងទៅ ក្នុងល័ក្ខខ័ណ្ឌដែលសុខភាព សុវត្ថិភាព និងសីលធម៌របស់កុមារ ត្រូវបានការពារ យ៉ាង ពេញលេញ ហើយថា កុមារបានទទួលការណែនាំជាក់លាក់គ្រប់គ្រាន់ ឬការបណ្តុះបណ្តាលវិជ្ជាជីវៈនៅក្នុងផ្នែកនៃសកម្មភាព ការងារដែលពាក់ព័ន្ធ ។

## III. ការអនុវត្តន៍

៥. (1) ព័ត៌មាន និងទិន្នន័យស្ថិតិលំអិតស្តីអំពីប្រភេទ និងទំហំនៃពលកម្មកុមារ ត្រូវចងក្រង និងធ្វើឱ្យមានបច្ចុប្បន្នភាពដើម្បីប្រើប្រាស់ធ្វើជាមូលដ្ឋានក្នុងការកំណត់អាទិភាពសំរាប់សកម្មភាពជាតិដើម្បីលុបបំបាត់ពលកម្មកុមា ជាពិសេសសំរាប់ការហាមប្រាម និងការលុបបំបាត់ទំរង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ ជាការប្រញាប់ ។

(2) ក្នុងករណីដែលអាចធ្វើទៅបាន ពត៌មាន និងទិន្នន័យស្ថិតិ ត្រូវរួមបញ្ចូលចំនួនសរុបតាមភេទ ក្រុមអាយុ មុខរបរ ផ្នែកនៃសកម្មភាពសេដ្ឋកិច្ច និងស្ថានភាពមុខរបរ ការចូលសាលារៀន និងទីតាំងភូមិសាស្ត្រ ។ សារៈសំខាន់នៃ ប្រព័ន្ធចុះបញ្ជី អត្រានុកូលដ្ឋាន រួមទាំងសំបុត្រកំណើត ក៏ត្រូវយកចិត្តទុកដាក់ផងដែរ ។

(3) ទិន្នន័យដែលពាក់ព័ន្ធទៅនឹងការរំលោភបំពានបទបញ្ញត្តិជាតិនានា សំរាប់ការហាមប្រាម និងការលុបបំបាត់ទំរង់ធ្ងន់ធ្ងរផុតនៃពលកម្មកុមារ ត្រូវចងក្រង និងធ្វើឱ្យមានបច្ចុប្បន្នភាព ។

៦. ការចងក្រង និងវិភាគពត៌មាន និងទិន្នន័យដែលបានលើកឡើងនៅក្នុងវាក្យខ័ណ្ឌទី ៥ ខាងលើ ត្រូវអនុវត្តដោយគោរពទៅតាមសិទ្ធិរក្សាការសំងាត់ ។

៧. ពត៌មានដែលបានចងក្រងនៅក្នុងវាក្យខ័ណ្ឌទី ៥ ត្រូវធ្វើឡើង ដោយមានការទំនាក់ទំនងជាមួយការិយាល័យអន្តរជាតិខាង ការងារដោយឈរលើមូលដ្ឋានជាទៀងទាត់ ។

៨. រដ្ឋជាសមាជិក ត្រូវរៀបចំបង្កើត ឬតែងតាំងយន្តការជាតិសមស្របនានា ដើម្បីតាមដានការអនុវត្តន៍បទបញ្ញត្តិជាតិស្តីពីការហាមប្រាម និងការលុបបំបាត់ទំរង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ ដោយការពិគ្រោះយោបល់ជាមួយអង្គការនិយោជក សហជីព ហើយប្រសិនបើអាចជាមួយក្រុមពាក់ព័ន្ធផ្សេងៗទៀត ។

៩. រដ្ឋជាសមាជិក ត្រូវធានាថា អាជ្ញាធរមានសមត្ថកិច្ចដែលមាននាទីទទួលខុសត្រូវ សំរាប់ការអនុវត្តន៍បទបញ្ញត្តិជាតិស្តីពីការហាមប្រាម និងការលុបបំបាត់ទំរង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ, ធ្វើកិច្ចសហការជាមួយគ្នាទៅវិញទៅមក និងសំរបសំរួលសកម្មភាពរបស់ពួកគេ ។

១០. ច្បាប់ជាតិ និងបទបញ្ញត្តិនានា និងអាជ្ញាធរមានសមត្ថកិច្ច ត្រូវកំណត់បុគ្គលដែលទទួលខុសត្រូវនៅក្នុងព្រឹត្តិការណ៍នៃករណីដែលមិនអនុវត្តតាមបទបញ្ញត្តិជាតិស្តីពីការហាមប្រាមនិងការលុបបំបាត់ទំរង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ ។

១១. ក្នុងករណីដែលការអនុវត្តមានលក្ខណៈស្របទៅនឹងបទបញ្ញត្តិជាតិ នោះរដ្ឋជាសមាជិក ត្រូវសហការជាមួយកិច្ចខិតខំប្រឹងប្រែងជាអន្តរជាតិ ក្នុងគោលដៅហាមប្រាម និងលុបបំបាត់ទំរង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ ដោយចាត់ទុកជាការប្រញាប់ដោយៈ

(ក) ធ្វើការប្រមែប្រមូល និងផ្លាស់ប្តូរពត៌មានដែលពាក់ព័ន្ធទៅនឹងបទឧក្រិដ្ឋ រួមមានអ្នកដែលពាក់ព័ន្ធទៅនឹងបណ្តាញអន្តរជាតិ ។

(ខ) ឃុំឃាំង និងកាត់ទោសអ្នកដែលជាប់ពាក់ព័ន្ធទៅនឹងការលក់ និងការជួញដូរកុមារ ឬការប្រើប្រាស់ការការអូសទាញ ឬផ្តល់ឱ្យកុមារធ្វើសកម្មភាពខុសច្បាប់នានា ដូចជាបេស្យាកម្ម ការផលិតរូបភាពអាសគ្រាម ឬការសំដែងអាសគ្រាម ។

(គ) ចុះបញ្ជីអ្នកប្រព្រឹត្តអំពើខុសច្បាប់បែបនេះ ។

១២. រដ្ឋជាសមាជិកត្រូវយល់ស្របថា អំពើឧក្រិដ្ឋដូចតទៅ នេះ គឺជាទំរង់ធ្ងន់ធ្ងបំផុតនៃពលកម្មកុមារ :

(ក) គ្រប់ទំរង់នៃទាសភាព ឬការអនុវត្តន៍បែបទាសភាព ដូចជាការលក់ ការជួញដូរកុមារ ឬការងារដោះបំណុល និងការងារជាខ្ញុំកញ្ជះគេ ការងារដោយបង្ខំ ឬដោយជាប់កាតព្វកិច្ច រួមមានការបង្ខំ ឬកាតព្វកិច្ចរបស់កុមារក្នុងជំលោះប្រដាប់អាវុធ ។

(ខ) ការប្រើប្រាស់ ការអូសទាញ ឬការផ្តល់ឱ្យកុមារធ្វើបេស្យាកម្ម ការផលិតរូបអាសគ្រាម ឬការសំដែងអាសគ្រាម និង

(គ) ការប្រើប្រាស់ ការអូសទាញ ឬការផ្តល់ឱ្យកុមារធ្វើសកម្មភាពខុសច្បាប់ មានជាអាទិ៍ ការផលិត និងការជួញដូរគ្រឿងញៀន ដូចដែលបានកំណត់ក្នុងសន្ធិសញ្ញាអន្តរជាតិពាក់ព័ន្ធនានាឬសកម្មភាពដែលពាក់ព័ន្ធទៅនឹងការងារក្រៅច្បាប់ ឬការប្រើប្រាស់អាវុធយុទ្ធភ័ណ្ឌខុសច្បាប់ ។

១៣. រដ្ឋជាសមាជិក ត្រូវធានាថា បទព្រហ្មទណ្ឌ រួមមាន ឧក្រិដ្ឋកម្មព្រហ្មទណ្ឌ ត្រូវបានអនុវត្តឱ្យបានសមស្រប ចំពោះការរំលោភបំពានបទបញ្ញត្តិជាតិស្តីពីការហាមប្រាម និងការលុបបំបាត់គ្រប់ប្រភេទនៃការងារដែលបានលើកឡើងនៅក្នុងមាត្រា ៣ (ឃ) នៃអនុសញ្ញា ។

១៤. រដ្ឋជាសមាជិក ត្រូវចាត់ទុកជាការប្រញាប់ សំរាប់វិធានការរដ្ឋបាល រដ្ឋប្បវេណី ឬ រដ្ឋបាលដើម្បីធានាប្រសិទ្ធិភាព នៃការជំរុញអនុវត្តបទបញ្ញត្តិជាតិស្តីពីការហាមប្រាម និងការលុបបំបាត់ទំរង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ ដូចជា ការចាត់វិធានការ ពិសេសចំពោះគ្រឹះស្ថានទាំងឡាយណាដែលមានប្រើប្រាស់ទំរង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ ហើយក្នុងករណីរំលោភបំពាន ត្រូវពិចារណាលើការដកហូតជាបណ្តោះអាសន្ន និងជាអចិន្ត្រៃយ៍នូវការអនុញ្ញាតិឱ្យប្រតិបត្តិការ ។

១៥. វិធានការផ្សេងៗទៀត ដែលមានគោលដៅហាមប្រាម និងលុបបំបាត់ទំរង់ធ្ងន់ធ្ងរបំផុតនៃពលកម្ម មានដូចតទៅ :

(ក) ការផ្តល់ព័ត៌មាន ការធ្វើឱ្យយល់ឲ្យដឹងជ្រាប និងបំផុសចលនាដល់សាធារណៈជនទូទៅ មានជាអាទិ៍ អ្នកដឹកនាំជាតិ និងតំបន់ សមាជិក-សមាជិកានៃអង្គការនីតិបញ្ញត្តិ និងតុលាការ ។

(ខ) ជំរុញឱ្យមានការចូលរួម និងការបណ្តុះបណ្តាលដល់អង្គការនិយោជក សហជីព និងអង្គការសង្គមផ្សេងៗទៀត ។

(គ) ផ្តល់ការបណ្តុះបណ្តាលសមស្រប សំរាប់មន្ត្រីរដ្ឋាភិបាលដែលពាក់ព័ន្ធ ជាពិសេសមន្ត្រីអធិការកិច្ចការងារ និងមន្ត្រីជំរុញ ការអនុវត្តន៍ច្បាប់ និងអ្នកពាក់ព័ន្ធផ្សេងទៀត ។

(ឃ) រៀបចំធ្វើការកាត់ទោសនៅក្នុងប្រទេសផ្ទាល់របស់ខ្លួន ចំពោះអ្នកប្រព្រឹត្តបទឧក្រិដ្ឋដែលមានសញ្ជាតិនៃប្រទេសជាសមាជិកក្រោមច្បាប់ជាតិស្តីពីការហាមប្រាម និងការលុបបំបាត់ជាបន្ទាន់នៃទំរង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ ហើយទោះបីជាការប្រព្រឹត្តទាំងនេះ កើតឡើងនៅក្នុងប្រទេសដទៃទៀតក៏ដោយ ។

(ង) ធ្វើឱ្យមានភាពងាយស្រួលចំពោះទំរង់បែបបទខាងផ្លូវច្បាប់ និងរដ្ឋបាល និងធានាថា ទំរង់បែបបទនេះសមស្រប និងរហ័ស ។

(ច) លើកទឹកចិត្តការកសាងគោលនយោបាយតាមរយៈការអនុវត្តន៍សកម្មភាព លើកកំពស់គោលបំណងនៃអនុសញ្ញា ។

(ឆ) តាមដានត្រួតពិនិត្យ និងផ្សព្វផ្សាយជាសាធារណៈ ស្តីពីបទពិសោធន៍ដ៏ប្រសើរនៃការលុបបំបាត់ពលកម្មកុមារ ។

(ជ) ផ្តល់ការផ្សព្វផ្សាយជាសាធារណៈ ស្តីពីច្បាប់ ឬបទបញ្ញត្តិស្តីពីពលកម្មកុមារជាច្រើនភាសា ឬជាភាសាកំណើត។

(ឈ) បង្កើតឡើងនូវទំរង់បែបបទនៃបណ្តឹងពិសេសនានា ហើយនឹងបទបញ្ញត្តិ ដើម្បីការពារអ្នកទាំងឡាយណាដែលបង្ហាញដោយស្របច្បាប់នូវការរំលោភបំពានបទបញ្ញត្តិនានានៃអនុសញ្ញា ពីការប្រកាន់ពូជសាសន៍ និងការគុំគួនតបត ក៏ដូច ជាការបង្កើតឡើងនូវបណ្តាញទំនាក់ទំនងសំរាប់ជំនួយគាំទ្រ និងអ្នកស៊ើបអង្កេតបណ្តឹងតវ៉ានានា ។

(ញ) អនុម័តវិធានការសមស្រប ដើម្បីធ្វើឱ្យប្រសើរឡើង នូវហេដ្ឋារចនាសម្ព័ន្ធអប់រំ និងការបណ្តុះបណ្តាលគ្រូបង្រៀន ដើម្បីឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់កុមារា និងកុមារី ។

(ដ) ប្រសិនបើអាចធ្វើទៅបាន យកចិត្តទុកដាក់លើកម្មវិធីសកម្មភាពជាតិ ដូចខាងក្រោម:

- (i) សេចក្តីត្រូវការសំរាប់ការបង្កើតមុខរបរ និងការបណ្តុះបណ្តាលជំនាញ សំរាប់ ឪពុក-ម្តាយ និងយុវជននៅក្នុងគ្រួសារនៃកុមារធ្វើការងារ ក្នុងលក្ខខ័ណ្ឌដែលបានគ្របដណ្តប់ដោយអនុសញ្ញា និង
- (ii) សេចក្តីត្រូវការសំរាប់ធ្វើឱ្យឲ្យត្រជ្រាបដល់ ឪពុក-ម្តាយ ចំពោះបញ្ហាកុមារធ្វើការងារនៅក្នុងលក្ខខ័ណ្ឌនានា ។

១៦. ធ្វើឱ្យប្រសើរឡើងនូវកិច្ចសហប្រតិបត្តិការ និង/ឬជំនួយឧបត្ថម្ភអន្តរជាតិ ក្នុងចំណោមរដ្ឋជាសមាជិក ស្តីពីការហាមប្រាម និងការលុបបំបាត់ប្រកបដោយប្រសិទ្ធិភាពនូវទំរង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ ត្រូវបំពេញបន្ថែមលើកិច្ចខិតខំប្រឹងប្រែងរបស់ជាតិ និងអាចរៀបចំ និងអនុវត្តដោយមានការពិគ្រោះយោបល់ជាមួយអង្គការ និយោជក សហជីព ។ កិច្ចសហប្រតិបត្តិការ និង/ជំនួយ ឧបត្ថម្ភអន្តរជាតិ ត្រូវរួមបញ្ចូលនូវ:

(ក) ការបំផុសចលនាធនធាន សំរាប់កម្មវិធីជាតិ និងអន្តរជាតិ

(ខ) ជំនួយគាំទ្រផ្លូវច្បាប់ទៅវិញទៅមក

(គ) ជំនួយឧបត្ថម្ភបច្ចេកទេស រួមទាំងការផ្លាស់ប្តូរពត៌មាន

(ឃ) ការឧបត្ថម្ភគាំទ្រផ្នែកអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គម កម្មវិធីលុបបំបាត់ភាពក្រីក្រ និងការអប់រំជាសកល ។